**សេចក្តីថ្លែងការណ៍បញ្ចប់បេសកកម្ម**

អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

លោកស្រីសាស្រ្តាចារ្យ រ៉ូណា ស្មីត

ភ្នំពេញ, ថ្ងៃទី ៩ ខែឧសភា ឆ្នាំ២០១៩

ខ្ញុំបានបញ្ចប់បេសកកម្មលើកទី៧ របស់ខ្ញុំ ក្នុងនាមជាអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ខ្ញុំសូមថ្លែងអំណរគុណដល់រដ្ឋាភិបាល ដែលបានអញ្ជើញខ្ញុំមកបំពេញទស្សនកិច្ចនាពេលនេះ និងឆន្ទៈរបស់មន្ត្រីរដ្ឋាភិបាលជាច្រើនរូបដែលបានយល់ព្រមជួបប្រជុំជាមួយខ្ញុំ និងពិភាក្សាដោយបើកចំហអំពីសិទ្ធិមនុស្ស និងការអភិវឌ្ឍប្រកបដោយចីរភាពនៅប្រទេសកម្ពុជា។ ខ្ញុំសូមសំដែងការកោតសរសើរផងដែរ ចំពោះការលះបង់ និងកិច្ចខិតខំប្រឹងប្រែងបំពេញការងាររបស់បុគ្គលិកទាំងអស់ របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ទាំងនៅប្រទេសកម្ពុជា និងនៅទីក្រុងហ្សឺណែវ ដែលបានគាំទ្រនិងរៀបចំសម្រួលបេសកកម្មរបស់ខ្ញុំប្រកបដោយសមត្ថភាព។

នៅក្នុងអំឡុងពេលបំពេញបេសកកម្មនេះ ខ្ញុំមានបុព្វសិទ្ធិជួបជាមួយមន្ត្រីជាន់ខ្ពស់មួយចំនួន ជាពិសេសជាមួយសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ឯកឧត្តម ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ព្រមទាំងលោកជំទាវ ហង់ លីណា អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ, ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល, ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ឯកឧត្តម ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ, ឯកឧត្តម កែវ រ៉េមី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា, ឯកឧត្តម យាង សេង អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ និងឯកឧត្តម នាយឧត្តមសេនីយ៍ មាស វីរិទ្ធ អគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ខ្ញុំមានសេចក្ដីរីករាយ ដែលឃើញរដ្ឋមន្ត្រីជាន់ខ្ពស់ជាច្រើននៃរដ្ឋាភិបាល បានយកឱកាសចែករំលែកព័ត៌មានស្ដីពីវឌ្ឍនភាព ក្នុងការឆ្លើយតបទៅនឹងអនុសាសន៍កន្លងមករបស់ខ្ញុំ ក៏ដូចជាធ្វើបច្ចុប្បន្នភាពស្ថានការណ៍វិវឌ្ឍន៍ រាប់ចាប់តាំងពីបេសកកម្មលើកមុនរបស់ខ្ញុំ។ ខ្ញុំបានជួបប្រជុំផងដែរ ជាមួយអ្នកពាក់ព័ន្ធជាច្រើនទៀត រួមមាន តំណាងសង្គមស៊ីវិល សហគមន៍ការទូត និងក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ លើសពីនេះទៀត ខ្ញុំបានជួបជាមួយប្រជាពលរដ្ឋ និងក្រុមប្រជាជនមួយចំនួន ដែលបានដាក់ញត្តិ ឬបានស្នើសុំជួបប្រជុំជាមួយខ្ញុំដោយផ្ទាល់។ ភាគច្រើននៃញត្តិទាំងនេះពាក់ព័ន្ធនឹងសិទ្ធិដីធ្លី។ ញត្តិដទៃផ្សេងទៀត ទាក់ទងទៅនឹងសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំ។

សម្រាប់បេសកកម្មនេះ ខ្ញុំបានបន្តផ្ដោតលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់សហប្រជាជាតិ។ មានវឌ្ឍនភាពដ៏សំខាន់មួយ ចាប់តាំងពីបេសកកម្មលើកមុនរបស់ខ្ញុំ គឺការអនុម័តផែនការមូលដ្ឋានូបនីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។ ខ្ញុំបានពិនិត្យឯកសារនេះយ៉ាងយកចិត្តទុកដាក់ ហើយខ្ញុំបានសម្គាល់ឃើញពីទំនាក់ទំនងគ្នារវាងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រដ្ឋាភិបាល និងផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិនាពេលខាងមុខ។

សិទ្ធិមនុស្សជាមូលដ្ឋានដែលមានក្នុងរបៀបវារៈឆ្នាំ២០៣០ ស្ដីពីការអភិវឌ្ឍប្រកបដោយចីរភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកល គួរតែជាមូលដ្ឋានផងដែរ សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា ។ មានចំណុចជាច្រើននៃផែនការមូលដ្ឋានូបនីយកម្ម ដែលឆ្លុះបញ្ចាំងអំពីទិដ្ឋភាពជាច្រើននៃសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

ទោះជាយ៉ាងណាក៏ដោយ ក៏ទិដ្ឋភាពសិទ្ធិមនុស្សសំខាន់ៗមួយចំនួននៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព មិនមានចែងនៅក្នុងផែនការមូលដ្ឋានូបនីយកម្មឡើយ។ ចំណុចសំខាន់បំផុតនោះគឺ ផែនការមូលដ្ឋានូបនីយកម្មកាត់បន្ថយយ៉ាងច្រើននូវគោលដៅ និងសូចនាករពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី១៦ ស្ដីពី «សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ» ។ បញ្ហានេះកាត់បន្ថយយ៉ាងខ្លាំងនូវមហិច្ឆតារបស់ប្រទេសកម្ពុជា ក្នុងការទទួលបានយុត្តិធម៌សម្រាប់ទាំងអស់គ្នា បញ្ចប់អំពើហិង្សា ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ពង្រឹងនីតិរដ្ឋ ធានាឲ្យមានការធ្វើការសេចក្ដីសម្រេចចិត្តប្រកបដោយការចូលរួម ធានាសិទ្ធិទទួលបានព័ត៌មាន ការពារសេរីភាពជាមូលដ្ឋាន អនុវត្តច្បាប់ដោយមិនរើសអើង និងកសាងស្ថាប័នជាតិរឹងមាំ។ សិទ្ធិមនុស្សមានសារៈសំខាន់ ក្នុងធានាសន្តិភាព និងការអភិវឌ្ឍ។ ដូចដែលខ្ញុំបានគូសបញ្ជាក់កន្លងមក សន្តិភាពដោយគ្មានយុត្តិធម៌ គឺគ្មានចីរភាពឡើយ ហើយការអភិវឌ្ឍដោយគ្មានសេរីភាព គឺជាការទុកប្រជាពលរដ្ឋចោល។

ខ្ញុំត្រូវបានលើកទឹកចិត្ត នៅក្នុងកិច្ចប្រជុំជាផ្លូវការ តាមរយៈការបង្ហាញឆន្ទៈក្នុងការបើកចំហផែនការមូលដ្ឋានូបនីយកម្ម និងដាក់បញ្ចូលគោលដៅ និងសូចនាករពាក់ព័ន្ធនឹងសិទ្ធិមនុស្សបន្ថែមទៀត។ **ដូច្នេះ ខ្ញុំសូមលើក**

**ទឹកចិត្តយ៉ាងខ្លាំងដល់ការដាក់បញ្ចូលគោលដៅដែលមានមហិច្ឆតានេះកាន់តែច្រើនថែមទៀត ក្នុងផែនការមូលដ្ឋានូបនីយកម្មទាក់ទងនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១៦ ។ ខ្ញុំបានលើកទឹកចិត្តផងដែរ ឲ្យមានការចូលរួមកាន់តែស៊ីជម្រៅខ្លាំងឡើងថែមទៀត ពីសំណាក់ក្រសួងយុត្តិធម៌ អង្គភាពប្រឆាំងអំពើពុករលួយ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធានាថាគោលនយោបាយសំខាន់ ត្រូវបានឆ្លុះបញ្ចាំង និងពន្លេចនៅក្នុងមូលដ្ឋានូបនីយកម្មរបស់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។**

រដ្ឋាភិបាលនឹងដាក់បង្ហាញរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តរបស់ខ្លួនស្តីពីការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពជូនអង្គការសហប្រជាជាតិនៅទីក្រុងញូយក ក្នុងខែកក្កដា ខាងមុខនេះ។ ខ្ញុំទទួលព័ត៌មានថារបាយការណ៍ជាតិស្តីពីការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត កំពុងត្រូវបានរៀបចំដល់ដំណាក់កាលចុងក្រោយ។ ការពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តផ្តល់ឱកាសដល់រដ្ឋាភិបាល ថ្លែងប្រាប់ដល់វេទិកាសកលលោក អំពីការអភិវឌ្ឍយ៉ាងឆាប់រហ័សនិងគួរឲ្យកត់សំគាល់ បន្ទាប់ពីប្រទេសកម្ពុជាបានចេញផុតពីអតីតកាលដ៏សោកនាដកម្មក្នុងរយៈពេលប៉ុន្មានទសវត្សកន្លងមកនេះ។ ខ្ញុំត្រូវបានលើកទឹកចិត្តដោយមានការដាក់បញ្ចូលសង្គមស៊ីវិលទៅក្នុងដំណើរការនៃការរៀបចំរបាយការណ៍នេះ ហើយខ្ញុំសូមលើកទឹកចិត្តរដ្ឋាភិបាលឲ្យបន្តពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលក្នុងការបញ្ចាប់របាយការណ៍ជាតិស្តីពីការពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត និងឆ្លុះបញ្ចាំងពីការរួមវិភាគទានរបស់ពួកគេទៅក្នុងសំណៅចុងក្រោយ។ ដំណើរការនេះនឹងជួយបង្ហាញថា ការចូលរួមបែបនេះមានអត្ថន័យជ្រាលជ្រៅ។ វាក៏អាចនាំទៅរកភាពជាដៃគូឲ្យកាន់តែរឹងមាំក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា។ ជាមួយនឹងការអនុម័តរបាយការណ៍នៃការពិនិត្យជាសកលតាមកាលកំណត់លើកទី៣ របស់កម្ពុជា ដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងកក្កដាខាងមុខនេះ ខ្ញុំសូមលើកទឹកចិត្ត រដ្ឋាភិបាលឲ្យចាត់ទុកថាការពិនិត្យទាំងពីរនេះ គឺជាការបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក។ **ខ្ញុំសូមគូសបញ្ជាក់ជាថ្មីម្តងទៀតអំពីអនុសាសន៍របស់ខ្ញុំដែលស្នើឱ្យរដ្ឋាភិបាលរៀបចំសន្និសីទថ្នាក់ជាតិមួយជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិ និងសង្គមស៊ីវិល ដើម្បីបន្តអនុវត្តលទ្ធផលនៃការត្រួតពិនិត្យដោយស្ម័គ្រចិត្តខាងលើ។**

## ការមិនរើសអើង និងសមភាព – ដោយមិនទុកនរណាម្នាក់ចោល

គោលការណ៍ចំបងនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺមិនត្រូវ**ទុកនរណាម្នាក់ចោលនោះទេ**។ គោលការណ៍នេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំងស្រុង និងពាក់ព័ន្ធជាពិសេសដល់គោលដៅទី៥ ស្តីពីសមភាពយេនឌ័រ និងការកាត់បន្ថយវិសមភាពនៅក្នុងគោលដៅទី១០ ព្រមទាំងការលើកកំពស់ និងការអនុវត្តន៍គោលនយោបាយ និងច្បាប់ដោយគ្មានការរើសអើង នៅក្នុងគោលដៅទី១៦។ **ការកំណត់អត្តសញ្ញាណអ្នកទាំងឡាយដែលប្រឈមនឹងហានិភ័យនៃការណ៍ដែលត្រូវគេទុកចោល គួរតែធ្វើ**

**ឡើងក្នុងក្របខ័ណ្ឌពេញលេញទូលំទូលាយ។ សំខាន់ជាងនេះ ការកំណត់នេះគួរបញ្ចូលអ្នកក្រីក្រ និងអ្នកស្ថិតនៅក្បែរបន្ទាត់ភាពក្រីក្រ និងការកំណត់ផ្សេងៗទៀត។**

អ្នកទាំងឡាយដែលប្រឈមនឹងហានិភ័យ គួររួមបញ្ចូលឲ្យបានទូលំទូលាយនូវបុគ្គល និងក្រុមនានា រួមមាន ស្ត្រី កុមារ ជនជាតិដើមភាគតិច អ្នកសុំសិទ្ធិជ្រកកោន ជនភៀសខ្លួន អ្នករស់នៅនិងធ្វើការតាមចិញ្ចើមថ្នល់ អ្នកប្រើប្រាស់គ្រឿងញៀន និងអ្នករស់នៅអាស្រ័យលើសារធាតុញៀន ជនជាប់ឃុំ ជនដែលមានពិការភាព អ្នកត្រូវគេបណ្តេញចេញពីលំនៅឋាន ខ្មែរអ៊ីស្លាម ជនជាតិភាគតិចវៀតណាម និងសហគមន៍ខ្មែរក្រោម អ្នកស្រលាញ់ភេទដូចគ្នា កម្មករធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ ពលករទេសន្តរប្រវេសន៍ និងមនុស្សចាស់។ អ្នកទាំងឡាយដែលប្រឈមនឹងហានិភ័យនៃការដែលត្រូវគេទុកចោល ក៏អាចមានវត្តមានក្នុងចំនួនដ៏ធំក្នុងខេត្តនិងតំបន់ជាក់លាក់នានា។ របាយការណ៍បណ្តោះអាសន្ននៃជំរឿនដែលបានធ្វើកាលពីខែមីនា នឹងត្រូវផ្សព្វផ្សាយនៅក្នុងខែមិថុនាខាងមុខនេះ។ ខ្ញុំជឿជាក់ថា លទ្ធផលបានមកពីជំរឿននេះ នឹងផ្តល់ទិន្នន័យបន្ថែមទៀត ដែលអាចជួយកំណត់អត្តសញ្ញាណកាន់តែច្បាស់ទៅលើអ្នកទាំងឡាយដែលប្រឈមនឹងហានិភ័យនៃការដែលត្រូវគេទុកចោល។ **ខ្ញុំសូមលើកទឹកចិត្តរដ្ឋាភិបាលឱ្យធ្វើការកំណត់អត្តសញ្ញាណឲ្យបានទូលំទូលាយទៅលើអ្នកទាំងឡាយដែលប្រឈមនឹងហានិភ័យនៃការដែលត្រូវគេទុកចោល និងបង្កើតកម្មវិធីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឲ្យចំទិសដៅ ដើម្បីធានាថាពួកគេត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍនានា។**

ក្នុងកំឡុងពេលទស្សនកិច្ចនេះ ខ្ញុំបានផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះស្ថានភាពនៃ**អ្នកប្រើប្រាស់គ្រឿងញៀន និងអ្នករស់នៅអាស្រ័យសារធាតុញៀន។** ខ្ញុំបានស្វែងយល់កាន់តែស៊ីជម្រៅអំពីការផ្តល់ការព្យាបាលនៅកម្ពុជា។ ខ្ញុំបានទៅទស្សនកិច្ចមន្ទីរពេទ្យបង្អែកមានជ័យ និងមជ្ឈមណ្ឌលស្តារនីតិសម្បទាឱកាសខ្ញុំ។ ខ្ញុំក៏បានជួបប្រាស្រ័យការងារជាមួយឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល, ឯកឧត្តម វង សូត្រ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងឯកឧត្តម មាស វិរិទ្ធ អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ ខ្ញុំ បានយល់ដឹងពីសេវាកម្មព្យាបាលដោយប្រើប្រាស់មេតាដូនសំរាប់អ្នកញៀនអាភៀន គឺជាសេវាកម្មមួយដែលអាចរកបានតែនៅបីមន្ទីរពេទ្យប៉ុណ្ណោះ។ ខ្ញុំក៏បានយល់ដឹងថែមទៀតពីវិសាលភាពនៃការប្រើប្រាស់សារធាតុសំយោគ ATS។

ខ្ញុំសូមស្វាគមន៍ចំពោះជំហានដែលរដ្ឋាភិបាលកំពុងចាត់ឡើងដើម្បីធ្វើឲ្យប្រសើរឡើងដល់ការព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀន និងសារធាតុញៀន ហើយកំណត់ជាអាទិភាពនូវការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ក្នុងភាពជាដៃគូ ទោះបីជាវាមិនទាន់បានឆ្លុះបញ្ចាំងយ៉ាងពេញលេញនៅឡើយនៅក្នុង

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។ កាលពីមួយឆ្នាំមុន ក្រសួងសុខាភិបាលបានអនុម័តគោលការណ៍ណែនាំស្តីពីការពិនិត្យ និងព្យាបាល អំពីកញ្ចប់អប្បបរមានៃសកម្មភាពសម្រាប់មណ្ឌលសុខភាព។ ក្រសួងក៏កំពុងផ្តល់ការបណ្តុះបណ្តាលដល់អ្នកផ្តល់ប្រឹក្សាយោបល់តាមសហគមន៍ផងដែរ។ ខ្ញុំសូមស្វាគមន៍ការយកចិត្តទុកដាក់លើការធ្វើសមាហរណកម្មអ្នកទាំងនេះទៅក្នុងសហគមន៍របស់ពួកគេ។ វាមានសារៈសំខាន់ណាស់ដែលអ្នកដែលទទួលរងផលប៉ះពាល់ ត្រូវបានផ្តល់ឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយថាគ្មានការរើសអើងប្រឆាំងនឹងពួកគេ នៅពេលពួកគេធ្វើសមាហរណកម្ម និងស្វែងរកការងារធ្វើ។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមានការព្រួយបារម្ភចំពោះការបន្តពឹងផ្អែកលើមជ្ឈមណ្ឌលស្តារនីតិសម្បទាដែលជាកន្លែងមិនបើចំហ ដូចជាមជ្ឈមណ្ឌលឱកាសខ្ញុំជាដើម ដែលនៅទីនោះ ជារឿយៗ មនុស្សត្រូវបានគេទទួលយកចូលបន្ទាប់ពីមានការព្រមព្រៀងរបស់ក្រុមគ្រួសារពួកគេ ហើយនឹងត្រូវបានដោះលែងវិញក្នុងករណីមានការព្រមព្រៀងរបស់ពួកគេ និងរបស់ក្រុមគ្រួសារ។ ខណៈដែលខ្ញុំយល់ពីសារៈសំខាន់នៃការបញ្ចប់កម្មវិធីស្តារនីតិសម្បទាទាំងឡាយ បញ្ហានេះបង្កឲ្យមានការព្រួយបារម្ភមួយដែលមនុស្សនៅក្នុងមជ្ឈមណ្ឌលទាំងនោះស្នាក់នៅដោយមិនមានការស្ម័គ្រចិត្ត ហើយដែលតម្រូវឲ្យមានការអនុញ្ញាតិចេញ-ចូល និងត្រូវបានត្រួតពិនិត្យតឹងរឹង។ គោលការណ៍សិទ្ធិមនុស្សស្តីពីការព្យាបាលគ្រឿងញៀន តម្រូវឲ្យការព្យាបាលត្រូវតែធ្វើឡើងតាមការស្ម័គ្រចិត្តនៅក្នុងសហគមន៍ ជាជាងការព្យាបាលដែលធ្វើឡើងដោយបង្ខិតបង្ខំនៅក្នុងទីកន្លែងមិនបើកចំហ។

ខ្ញុំក៏បានធ្វើទស្សនកិច្ចទៅកាន់មជ្ឈមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ (មជ្ឈមណ្ឌលព្រៃស្ពឺ) ផងដែរ។ មនុស្សដែលស្នាក់នៅនៅក្នុងមជ្ឈមណ្ឌលនេះ មិនត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយទេដែលធ្វើឱ្យមានការព្រួយបារម្ភអំពីការឃុំឃាំងដោយបំពាន។ ខ្ញុំសូមអំពាវនាវដល់អាជ្ញាធរ ឲ្យមានការការពារប្រឆាំងនឹងការឃុំឃាំងតាមអំពើចិត្តនៅក្នុងមជ្ឈមណ្ឌលនេះ។ លើសពីនេះទៀត ខ្ញុំសូមអំពាវនាវដល់អាជ្ញាធររាជធានី និងអាជ្ញាធរជាតិពាក់ព័ន្ធ ឲ្យអនុវត្តតាមអនុសាសន៍ដែលបានព្រមព្រៀងគ្នានៅក្នុង**សន្និសីទថ្នាក់ជាតិឆ្នាំ ២០១៥ ស្តីពីស្ថានភាពជនរស់នៅតាមចិញ្ចើមផ្លូវ** និងធ្វើការងារយ៉ាងជិតស្និទ្ធជាមួយក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស និងអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធទៅលើបញ្ហានេះ។

នៅអំឡុងបេសកកម្មលើកនេះ ខ្ញុំបានធ្វើដំណើរទស្សនកិច្ចតាមដានស្ថានភាពនៅខេត្តកំពង់ឆ្នាំង ដោយបានត្រឡប់ទៅជួបប្រជាជនមកពីសហគមន៍បណ្តែតទឹកដែលរដ្ឋបាលខេត្តបានប្តូរឲ្យទៅរស់នៅលើដីគោក។ អ្នកភូមិទាំងនេះរួមមានជនជាតិខ្មែរ ខ្មែរឥស្លាម និងជនជាតិវៀតណាម។ ពួកគេគឺជាអ្នកក្រីក្រហើយប្រឈមនឹងការទុកចោល។ ពួកគេជាច្រើនកំពុងតែរស់នៅជាបណ្តោះអាសន្ន និងខ្លះរស់នៅជាអចិន្ត្រៃយ៍លើតំបន់តាំងទីលំនៅថ្មី។ សម្រាប់តំបន់តាំងទីលំនៅថ្មីនានា ត្រូវតែមាន ទឹក អនាម័យ អគ្គីសនី និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការផ្តល់ឲ្យមាននូវមធ្យោបាយទ្រទ្រង់ជីវភាពសមស្របដើម្បីគាំទ្រដល់ជីវភាពរស់នៅសមរម្យ។

ខ្ញុំមានការព្រួយបារម្ភជាខ្លាំងអំពីកម្រិតនៃសំណល់រឹង/ប្លាស្ទិក និងសំណល់រាវដែលមិនមានសុវត្ថិភាពនៅតំបន់តាំងទីលំនៅថ្មីបណ្តោះអាសន្ន ជាពិសេសនៅតំបន់ផ្ទុកទ្រូ ដែលនឹងបណ្តាលឲ្យមានការបំពុលយ៉ាងធ្ងន់ធ្ងរនៅពេលកំពស់ទឹកកើនឡើងជាបន្តបន្ទាប់ ហើយដែលវានឹងមានផលប៉ះពាល់អវិជ្ជមានលើសិទ្ធិនិងសុខភាពរបស់អ្នករស់នៅទីនោះ។ ខ្ញុំក៏មានការព្រួយបារម្ភផងដែរថា ផ្ទះជាច្រើនដែលបានផ្លាស់ទីបណ្តោះអាសន្ន និងផ្លាស់ទីជាអចិន្ត្រៃយ៍មកកាន់ទីតាំងថ្មីនេះ ស្ថិតនៅក្រោមកម្រិតនៃកម្ពស់ទឹក ប៉ុន្តែផ្ទះទាំងនោះនឹងមិនអាចអណ្តែតលើផ្ទៃទឹកនៅពេលមានទឹកជន់លិច។

ខ្ញុំទទួលបានការបញ្ជាក់ថា អាជ្ញាធរខេត្តបានយល់ព្រមមិនផ្លាស់ប្តូរទីលំនៅសហគមន៍ទាំងនេះទៅកាន់តំបន់តាំងទីលំនៅថ្មីអចិន្ត្រៃយ៍ទៀតទេ រហូតទាល់តែមានហេដ្ឋារចនាសម្ព័ន្ធនានាជាមុនសិន។ ខ្ញុំលើកទឹកចិត្តអាជ្ញាធរឲ្យមានការធានាថា រាល់ទីតាំងសម្រាប់ការតាំងទីលំនៅថ្មី ទាំងការតាំងលំនៅបណ្តោះអាសន្ន និងជាអចិន្ត្រៃ ហើយដែលប៉ះពាល់សហគមន៍ទាំងអស់ ត្រូវតែមានហេដ្ឋារចនាសម្ព័ន្ធចាំបាច់ជាមុនសិន។

ជាចុងក្រោយ ប្រជាពលរដ្ឋដែលពុំមានប័ណ្ណកម្មសិទ្ធិដីច្បាស់លាស់ ឬអ្នកដែលត្រូវបានបណ្តេញចេញពីដីធ្លីរបស់ខ្លួនគឺប្រឈមនឹងការទុកចោល។ ខ្ញុំសូមស្វាគមន៍ចំពោះ វឌ្ឍនភាពនៃការចុះបញ្ជីដីធ្លី និងការដោះស្រាយវិវាទដីធ្លី។ ទោះបីជាយ៉ាងណា ខ្ញុំស្នើដល់រដ្ឋាភិបាលឲ្យធានាថា រាល់ដំណោះស្រាយត្រូវតែមានភាពគ្រប់ជ្រុងជ្រោយនិងច្បាស់លាស់ គ្របដណ្តប់លើគ្រប់អ្នកពាក់ព័ន្ធទាំងអស់ និងដំណើរការដោះស្រាយវិវាទត្រូវធ្វើឡើងប្រកបដោយតម្លាភាព។ ជាពិសេស វាមានសារៈសំខាន់ណាស់ដែលរាល់ដំណោះស្រាយទាំងអស់ ត្រូវរួមបញ្ចូលនូវអំណះអំណាងផ្សេងៗទាំងអស់ រួមទាំងអំណះអំណាងរបស់សហគមន៍ជនជាតិដើមភាគតិច។ អាស្រ័យហេតុនេះ សំណងសម្រាប់វិវាទមួយនឹងមិននាំឱ្យកើតមានជម្លោះបន្ថែមទៀតនោះទេ។

**ការចូលរួម**

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជំរុញឲ្យមានការអនុវត្តប្រកបដោយអត្ថន័យនៅកម្រិតមួយចំនួន។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព លេខ ១៧ គូសបញ្ជាក់ពីសារៈសំខាន់នៃភាពជាដៃគូ រួមទាំងសង្គមស៊ីវិលក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព លេខ ១៦ គូសបញ្ជាក់ពីការធ្វើសេចក្តីសម្រេចចិត្ត ដែលមានលក្ខណៈឆ្លើយតប បរិយាប័ន្ន ចូលរួម និង ជាតំណាងនៅគ្រប់កម្រិតទាំងអស់។

ខ្ញុំត្រូវបានលើកទឹកចិត្តដោយចាត់ចំណាត់ការវិជ្ជមានមួយចំនួន ចាប់តាំងពីបេសកកម្មលើកមុនរបស់ខ្ញុំ។ ជំហានវិជ្ជមានទាំងនេះរួមមាន ជាពិសេសការចាប់ផ្តើមដំណើរការវិសោធនកម្មច្បាប់ ស្តីពីសហជីព និងការបើកចំហជាបន្តបន្ទាប់ ដើម្បីពិនិត្យឡើងវិញលើច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ការរៀបចំវេទិកាភាពជាដៃគូថ្នាក់ជាតិលើកទី២ ជាមួយអង្គការសង្គមស៊ីវិល នៅខែមករា និង គោលការណ៍ណែនាំច្បាស់លាស់ដល់អាជ្ញាធរខេត្ត ដើម្បីរៀបចំកិច្ចពិគ្រោះយោបល់ស្រដៀងគ្នានៅក្នុងដែនសមត្ថកិច្ចរបស់ពួកគេ។

ដូចបានកត់សម្គាល់ខាងលើ ខ្ញុំដឹងអំពីកិច្ចពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលក្នុងការរៀបចំរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត។

ខ្ញុំក៏ទទួលស្គាល់ផងដែរថា គោលការណ៍ណែនាំទូទៅ ដែលបានចេញកាលពីខែតុលា និងវិច្ឆិកា ឆ្នាំមុន ដែលលុបចោលនូវសេចក្ដីជូនដំណឹងជាមុនរយៈពេលបីថ្ងៃនោះហាក់ដូចជាត្រូវបានគេអនុវត្តដដែល។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំសោកស្ដាយថា មិនមែនគ្រប់សមាគម និង អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ទទួលបាននូវសេរីភាព និង សិទ្ធិពេញលេញក្នុងការប្រតិបត្តិការសកម្មភាពរបស់ពួកគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការរាំងស្ទះ អនុលោមតាមច្បាប់ជាធរមាន ដូចដែលបានសន្យាដោយគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃឡើយ។ ជាការពិត ខ្ញុំបានទទួលរបាយការណ៍ជាច្រើនដែលនគរបាលនៅតាមមូលដ្ឋានបានចូលរួមក្នុងកម្មវិធីនានា ការបណ្តុះបណ្តាល ឬ ការប្រជុំដោយមិនបានអញ្ជើញឲ្យចូលរួម ដើម្បីថតរូប សួរដេញដោលអំពីអ្នករៀបចំ និង របៀបវារៈ ឬ សុំឈ្មោះ និង ព័ត៌មានស្ដីពីអ្នកចូលរួម។ ខ្ញុំបានទទួលព័ត៌មានផងដែរ អំពីតំណាងសង្គមស៊ីវិល និង ក្រុមគ្រួសាររបស់ពួកគេដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការឃ្លាំមើល។

ខ្ញុំចាត់ទុកការឃ្លាំមើលរបស់នគរបាលបែបនេះថា មិនមានលក្ខណៈស្របតាមស្មារតីនៃសេចក្ដីណែនាំ និង សេចក្ដីថ្លែងការណ៍កាលពីឆ្នាំមុន ស្ដីពីការលើកកម្ពស់ភាពជាដៃគូពិតប្រាកដជាមួយសង្គមស៊ីវិលឡើយ។ ខ្ញុំសូមលើកទឹកចិត្តដល់អង្គការនានាដែលកំពុងប្រឈមមុខនឹងបញ្ហាបែបនេះ ឲ្យប្រើប្រាស់យន្តការដែលបង្កើតឡើងដោយរដ្ឋាភិបាល និង រាយការណ៍ជាប្រព័ន្ធពីឧប្បត្តិហេតុទាំងនេះ សម្រាប់ជាព័ត៌មាន និង វិធានការកែតម្រូវ។ ខ្ញុំក៏បានស្នើសុំឲ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពង្រឹងសាររបស់គាត់ ស្ដីពីបរិយាកាសមួយដែលអង្គការទាំងនោះអាចមានលទ្ធភាពធ្វើការបានជាមួយអាជ្ញាធរនៅថ្នាក់ក្រោមជាតិ ។

ខ្ញុំបានយកចិត្តទុកដាក់ជាពិសេស ចំពោះបញ្ហាទូទៅស្តីពីសិទ្ធិមនុស្ស និងការតស៊ូមតិដើម្បីសិទ្ធិមនុស្ស ។ ក្នុងន័យនេះ ខ្ញុំមានការសោកស្តាយ ចំពោះការបំពេញការងារ និងការតស៊ូមតិ ដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស បែរជាត្រូវបានគេបន្តចាត់ទុកថាជាផ្នែកមួយនៃគណបក្សប្រឆាំង ឬមានការគាំទ្រគណបក្សប្រឆាំងទៅវិញ។ ជាការគួរសោកស្តាយ ដែលការចាត់ទុកបែបនេះត្រូវបានអនុវត្តចំពោះអាណត្តិរបស់ខ្ញុំ ព្រមទាំងអង្គការសិទ្ធិមនុស្សកម្ពុជាដទៃទៀតផងដែរ ។ នៅគ្រប់បណ្តាប្រទេសទាំងអស់ បញ្ហាសិទ្ធិមនុស្សអាចជាចំណុចរសើបផ្នែកនយោបាយ ហើយខ្លឹមសារនៃសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយគឺទាក់ទងនឹងលំហនយោបាយ។ ទោះជាយ៉ាងណាក៏ដោយ ភាសាសិទ្ធិមនុស្សគួរតែត្រូវបានគេមើលឃើញថាជាភាសារបស់មនុស្សគ្រប់រូប ទាំងរដ្ឋាភិបាល និងប្រជាជន ហើយខណៈពេលដែលការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស គឺជាការទទួលខុសត្រូវរួម វាគឺជាភាពស្របច្បាប់ដែលសង្គមស៊ីវិលទាមទាឲ្យរដ្ឋាភិបាលដែលជាអ្នកមានកាតព្វកិច្ចចម្បងខាងសិទ្ធិមនុស្ស ទទួលខុសត្រូវចំពោះសកម្មភាព និងគោលនយោបាយនានារបស់ខ្លួន។

ដូច្នេះខ្ញុំសង្ឃឹមថា ក្នុងស្មារតីនៃភាពជាដៃគូដ៏ពិតប្រាកដជាមួយសង្គមស៊ីវិល និងក្នុងទិដ្ឋភាពទាំងអស់នៃការអភិវឌ្ឍ វេទិកានានារបស់សង្គមស៊ីវិលនាពេលអនាគតនឹងផ្តល់នូវការកសាងទំនុកចិត្ត ការគោរព និងការសន្ទនាគ្នារវាងរដ្ឋាភិបាលនិងសង្គមស៊ីវិលពាក់ព័ន្ធនានា រួមទាំងអ្នកដែលធ្វើការងារផ្នែកតស៊ូមតិផងដែរ។

ក្នុងស្មារតីនេះដែរ ខ្ញុំសូមបញ្ជាក់ម្តងទៀត ការលើកទឹកចិត្តរបស់ខ្ញុំដល់រដ្ឋាភិបាល ជាពិសេសអជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងការគោរពសេរីភាពជួបប្រជុំដោយសន្តិវិធី។ ខ្ញុំទទួលស្គាល់ថា ការប្រមូលផ្តុំពាក់ព័ន្ធនឹងករណីដីធ្លី ជាពិសេស សហគមន៍ដែលធ្វើដំណើរមករាជធានីភ្នំពេញដើម្បីដាក់ញត្តិជូនអាជ្ញាធរពាក់ព័ន្ធ ត្រូវបានអនុញ្ញាត។ ក៏ប៉ុន្តែ ខ្ញុំកត់សម្គាល់ឃើញថា ការអនុញ្ញាតហែរក្បួននៅទិវាមនុស្ស ទិវាសិទ្ធិនារីអន្តរជាតិ និងទិវាពលកម្មអន្តរជាតិ ត្រូវបានបដិសេធដោយសារតែមានហេតុផលថា អាចមានការរំខានដល់ចរាចរ។ ខ្ញុំសូមរំលឹកថា គោលការណ៍ណែនាំសម្រាប់អនុវត្ត ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី គួសបញ្ជាក់ថាកាប៉ះពាល់ដល់ចរាចរមិនមែនជាមូលដ្ឋានដើម្បីបដិសេធការស្នើសុំហែរក្បួននោះឡើយ។ **បុគ្គលគ្រប់រូបមានសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិខាងសមាគម ក្នុងនោះរួមមានទាំងការចូលរួមអបអរសាទរប្រារព្ធទិវាជាតិ និងអន្តរជាតិនានាផងដែរ។ រាល់ការរឹតត្បិត ត្រូវតែធ្វើឡើងដោយផ្អែកលើភាពចាំបាច់ ហើយឆ្លុះបញ្ចាំងពីគោលការណ៍ណែនាំសម្រាប់អនុវត្តនៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ។**

**លើសពីនេះទៅទៀត ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាល ចៀសវាងការប្រើកំលាំងហួសហេតុនៅក្នុងការគ្រប់គ្រងលើការប្រមូលផ្តុំ។** ខ្ញុំសូមស្វាគមន៍ ចំពោះការក្រើនរំលឹករបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលថា កងកម្លាំងយោធាមិនត្រូវបានគេប្រើប្រាស់ដើម្បីគ្រប់គ្រងលើការធ្វើបាតុកម្ម និងការតវ៉ាណាមួយឡើយ។ ខ្ញុំសូមជំរុញលើកទឹកចិត្តរដ្ឋាភិបាលឲ្យធានាថា រាល់ការប្រព្រឹត្តិ និងការអនុវត្តណាមួយដែលមិនត្រឹមត្រូវ ត្រូវតែទទួលនូវការស៊ើបអង្កេត ដាក់ទណ្ឌកម្ម និងការទប់ស្កាត់ ដោយសមស្រប។

**ការចូលរួមប្រកបដោយអត្ថន័យនៅក្នុងអភិបាលកិច្ច និងការអភិវឌ្ឍ ក៏បានរួមបញ្ចូលផងដែរនូវសិទ្ធិចូលរួមចំណែកនៅក្នុងការរៀបចំកិច្ចការសាធារណៈ ដោយផ្ទាល់ ឬតាមរយៈតំណាងដែលបានជ្រើសរើសដោយ សេរី។** នៅក្នុងករណីនេះ ខ្ញុំបានស្វាគមន៍ចំពោះការលើកលែងទោសដោយព្រះមហាក្សត្រ និងការដោះលែងសមាជិក និងសកម្មជនគណៈបក្សប្រឆាំងមួយចំនួនកាលពីខែវិច្ឆិកាកន្លងទៅ ហើយបានអំពាវនាវឲ្យមានការ ដោះលែងឯកឧត្តម កឹម សុខា ពីការឃុំខ្លួនដោយមានលក្ខខណ្ឌ និងពន្លឿនការបិទការស៊ើបសួរលើសំណុំរឿង របស់គាត់។ ខ្ញុំកត់សម្គាល់ចំពោះការអនុម័តវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយកាលពីខែធ្នូកន្លងទៅ ដែលអនុញ្ញាតិឲ្យបុគ្គលដែលត្រូវបានហាមឃាត់ធ្វើសកម្មភាពនយោបាយដោយតុលាការកំពូលកាលពីលើកមុន អាចស្នើសុំ

សិទ្ធិធ្វើសកម្មភាពនយោបាយឡើងវិញ តាមរយៈនាយករដ្ឋមន្ត្រីទៅព្រះមហាក្សត្រ។ ខ្ញុំក៏កត់សម្គាល់ផងដែរថា មានបុគ្គលចំនួន៩រូប ក្នុងចំណោម១១៨ រូប ដែលត្រូវបានហាមឃាត់ បានសម្រេចចិត្តប្រើប្រាស់ បទប្បញ្ញត្តិនៃវិសោធនកម្មច្បាប់នេះ និងត្រូវបានស្តារនីតិសម្បទាឡើងវិញ។

ទោះបីជាយ៉ាងណាក៏ដោយ ចាប់តាំងពីបេសកម្មចុងក្រោយរបស់ខ្ញុំ ខ្ញុំបានឃើញការវិវឌ្ឍជាក់ស្តែងមួយចំនួន នៅក្នុងការប្រើប្រាស់សិទ្ធិនយោបាយ។ ខ្ញុំនៅតែមានការបារម្ភ ចំពោះការដាក់សម្ពាធទៅលើសមាជិករបស់គណបក្សសង្គ្រោះជាតិដែលបានរំលាយ នៅតែកើតមានឡើងជាបន្តបន្ទាប់។ យ៉ាងហោចណាស់មានការផ្តន្ទាទោសចំនួន៦ ត្រូវបានប្រកាសឡើងដោយតុលាការកម្ពុជា ចាប់តាំងពីបេសកម្មចុងក្រោយរបស់ខ្ញុំ ប្រឆាំងនឹងសមាជិក និងអ្នកគាំទ្រមួយចំនួនរបស់គណបក្សនេះ។ ខ្ញុំក៏បានដឹងផងដែរអំពីចំណាត់ការនានាដែលបានធ្វើដោយនគរបាល ឬតុលាការប្រឆាំងនឹងអតីតសមាជិក និងមន្ត្រីជាប់ឆ្នោតរបស់គណៈបក្សសង្គ្រោះជាតិចំនួន៨០ រូប នៅថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងដីកាកោះហៅចំនួន២៥ដែលចេញដោយសាលាដំបូងខេត្តបាត់ដំបងនៅក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ។ ចំពោះទស្សនៈរបស់ខ្ញុំ ចំណាត់ការបែបនេះ មិនអាចនាំទៅរកការពង្រឹងសិទ្ធិនយោបាយ និងលំហប្រជាធិបតេយ្យ ដូចដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកាលពីខែធ្នូកន្លងទៅបាននោះទេ។

**ខ្ញុំបានដឹងជ្រួតជ្រាបអំពីវោហារសាស្ត្រឆ្លងឆ្លើយគ្នាជាញឹកញាប់ពីសំណាក់ភាគីទាំងសងខាង និងជឿជាក់ថា នឹងមានតម្រូវការផ្លាស់ប្តូរវប្បធម៌នយោបាយតែមួយ ដែលផ្តោតទៅលើបញ្ហា ជាជាងផ្តោលើបុគ្គល។ ករណីនេះរួមជាមួយនឹងការការពារដោយច្បាប់នៃសេរីភាពបញ្ចេញមតិ អាចជួយឲ្យមានភាពជោគជ័យលើបញ្ហាប្រឈមនានានៃស្ថានភាពនយោបាយបច្ចុប្បន្ន សម្រាប់ជាផលប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាទាំងមូល។ ខ្ញុំក៏សូមអំពាវនាវដល់រដ្ឋាភិបាល ឲ្យពិនិត្យឡើងវិញលើច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់បោះឆ្នោតមួយចំនួន ដើម្បីឲ្យច្បាប់ទាំងនោះស្របជាមួយនឹងបទដ្ឋានអន្តរជាតិ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។**

ទាក់ទងនឹងការឃុំខ្លួនដែលនៅតែបន្តលើឯកឧត្តម កឹម សុខា ខ្ញុំកត់សម្គាល់លើការវិភាគបច្ចេកទេសច្បាប់របស់ក្រសួងយុត្តិធម៌ដែលថា ឯកឧត្តម កឹម សុខា ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយចៅក្រមអនុវត្តវិធានការដើម្បីធានាសុវត្ថិភាពរបស់គាត់។ ផ្អែកលើច្បាប់អន្តរជាតិ គាត់នៅតែស្ថិតនៅក្នុងការឃុំខ្លួន ដែលឈានទៅដល់ការរឹតត្បិតលើសេរីភាពបន្លាស់ទីរបស់គាត់ ការតាមឃ្លាំមើលសកម្មភាពរបស់ក្រុមគ្រួសារ និងមិត្តភក្ត្រនៅពេលដែលពួកគេមកសួរសុខទុក្ខគាត់ ព្រមទាំងការរឹតត្បិតចំពោះអ្នកដែលអាចមកសួរសុខទុក្ខគាត់។ ខ្ញុំត្រូវបានបដិសេធជួបជាមួយគាត់ជាថ្មីម្តងទៀត ហើយខ្ញុំក៏មានការសោកស្តាយផងដែរដែលចៅក្រមស៊ើបសួរ មិនអាចជួបជាមួយខ្ញុំបាន។ ខ្ញុំក៏មានការព្រួយបារម្ភផងដែរអំពីសិទ្ធិទទួលបានសុខភាពល្អ និងសូមលើកទឹកចិត្តដល់អាជ្ញាធរទាំងឡាយ អនុញ្ញាតិឲ្យគាត់បានស្វែងរកការព្យាបាលជំងឺ។ **ខ្ញុំសូមអំពាវនាវជាថ្មី**

**ម្តងទៀតឲ្យមានការដោះលែងឯកឧត្តម កឹម សុខា ចេញពីការឃុំខ្លួន និងពន្លឿនការបិទការស៊ើបសួរ ឬទម្លាក់ការចោទប្រកាន់មកលើរូបគាត់។**

**គណនេយ្យភាព**

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបទដ្ឋានសិទ្ធិមនុស្ស តម្រូវឲ្យមានគណនេយ្យភាព ក្នុងទម្រង់នៃការលើកកម្ពស់តម្លាភាព និងសុចរិតភាពនៅក្នុងការធ្វើសេចក្តីសម្រេចរបស់រដ្ឋាភិបាល ផ្តល់ព័ត៌មានការលៃបម្រុងថវិកា ការប្រយុទ្ធប្រឆាំងនឹងការសូកប៉ាន់ និងអំពើពុករលួយ ព្រមទាំងធានាឲ្យមានការទទួលបានយុត្តិធម៌ស្មើៗគ្នាសម្រាប់ទាំងអស់គ្នា។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី ១៦ គឺជាឯកសារយោងមួយដ៏សំខាន់បំផុតទៅលើគណនេយ្យភាព **ប៉ុន្តែគណនេយ្យភាពគឺជាគោលការណ៍មួយដែលគួរតែអនុវត្តនៅគ្រប់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំងអស់។**

ដំបូងបង្អស់ គណនេយ្យភាពដែលមានចែងនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព តម្រូវឲ្យមានស្ថាប័នរឹងមាំ ដែលធ្វើប្រតិបត្តិការដោយតម្លាភាព និងបើកចំហ ឲ្យមានការត្រួតពិនិត្យជាសាធារណៈ តាមរបៀបដែលស្ថាប័នទាំងនោះសន្យាសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ក្នុងន័យនេះ ការយកចិត្តទុកដាក់ជាសារវន្តចាំបាច់ត្រូវផ្តោតលើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ខ្ញុំមានសេចក្តីរីករាយដែលបានទទួលព័ត៌មានពី**ក្រសួងយុត្តិធម៌** ថា តុលាការទាំងអស់នាពេលបច្ចុប្បន្ននេះដាក់បង្ហាញឲ្យឃើញយ៉ាងច្បាស់នូវតារាងតម្លៃសេវាដែលអនុញ្ញាតឲ្យយក។ ខ្ញុំសូមលើកទឹកចិត្តដល់ក្រសួងឲ្យបន្តធ្វើបច្ចុប្បន្នភាពលើការដាក់បង្ហាញថ្លៃសេវាទាំងនេះ និងរៀបចំឲ្យសាធារណជនងាយមើលឃើញ។ ខ្ញុំក៏មានសេចក្តីរីករាយផងដែរចំពោះ**សេវាច្រកចេញចូលតែមួយ** ដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានពន្យល់ខ្ញុំកាលពីឆ្នាំមុន ដោយរាប់ទាំងការជូនដំណឹងជា សាធារណៈអំពីថ្លៃសេវាទាំងអស់នៅថ្នាក់ក្រោមជាតិ។

ទោះជាយ៉ាងណាក៏ដោយ វាចាំបាច់ត្រូវមានការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការប្រយុទ្ធប្រឆាំងនឹង**អំពើពុករលួយ**នៅកម្ពុជា ដូចដែលត្រូវបានទទួលស្គាល់ដោយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រដ្ឋាភិបាល។ ស្ថាប័នតុលាការមានជាប់ពាក់ព័ន្ធជាពិសេសនឹងបញ្ហានេះ ដោយហេតុថា ស្ថាប័នតុលាការខ្លួនឯងគឺជាគន្លឹះក្នុងការធានាឲ្យមានគណនេយ្យភាព។ ខ្ញុំសូមលើកទឹកចិត្តក្រសួងយុត្តិធម៌ឲ្យពិនិត្យមើលឲ្យបានលម្អិតលើសុចរិតភាពរបស់តុលាការ និងអំពើពុករលួយនៅក្នុងវិស័យតុលាការ។

គណនេយ្យភាពប្រកបដោយប្រសិទ្ធភាព ក៏ទាមទារឲ្យមានការទទួលបាននូវយុត្តិធម៌ប្រកបដោយប្រសិទ្ធភាពដូចគ្នា។ ជាថ្មីម្តងទៀត ខ្ញុំសូមអំពាវនាវឲ្យមានការអនុម័តគោលនយោបាយជំនួយផ្នែកច្បាប់ ឲ្យបានឆាប់រហ័ស។ បន្ថែមពីលើជំនួយផ្នែកច្បាប់ដែលបានផ្តល់តាមរយៈក្រសួងយុត្តិធម៌។ ក្រសួងយុត្តិធម៌ក៏បានជូនដំណឹងដល់ខ្ញុំនូវមូលនិធិបន្ថែមដើម្បី ផ្តល់ជំនួយផ្នែកច្បាប់ដល់ស្ត្រី។ ខ្ញុំសូមលើកទឹកចិត្ត ឲ្យមានការអនុវត្តឱ្យបានស៊ីសង្វាក់គ្នានូវមូលនិធិជំនួយផ្នែកច្បាប់នានា ដើម្បីធានាថាការគាំទ្រផ្នែកច្បាប់នេះបានទៅដល់អ្នកដែលត្រូវ

ការសេវានេះបំផុត។ ក្រសួងយុត្តិធម៌ក៏បានធ្វើបច្ចុប្បន្នភាពដល់ខ្ញុំ អំពីផែនការពង្រីកមជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌ និងការសាងសង់សាលាឧទ្ធរណ៍ថ្នាក់តំបន់ផងដែរ។ ខ្ញុំរំពឹងថា គំនិតផ្តួចផ្តើមទាំងនេះនឹងជួយធានាថាយុត្តិធម៌អាចប្រើប្រាស់និងទទួលបានច្រើនឡើងសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។

ខ្ញុំនៅតែមានការព្រួយបារម្ភចំពោះអត្រានៃ**ការឃុំខ្លួនបណ្តោះអាសន្ន**នៅកម្ពុជា។ ខណៈពេលដែលខ្ញុំស្វាគមន៍ចំពោះការចង្អុលបង្ហាញរបស់ក្រសួងយុត្តិធម៌អំពីជម្រើសផ្សេងជំនួសឱ្យការឃុំខ្លួន ខ្ញុំក៏សូមជំរុញដល់ក្រសួង ក្នុងការលើកទឹកចិត្តដល់ចៅក្រមក្នុងការសំរេចលើការឃុំខ្លួនបណ្តោះអាសន្ន ដែលធ្វើទៅបានតែក្នុងករណីចាំបាច់បំផុត ដោយអនុលោមតាមច្បាប់កម្ពុជា។ ពន្ធនាគារនៅកម្ពុជាកំពុងមានភាពចង្អៀតណែនយ៉ាងខ្លាំង ដោយក្នុងនោះមានជនជាប់ឃុំច្រើនជាងពាក់កណ្តាលត្រូវបានចោទប្រកាន់ ផ្តន្ទាទោស និងឃុំខ្លួន ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។ ដូច្នេះ គេត្រូវធានាថាការឃុំខ្លួនមនុស្សនៅក្នុងពន្ធនាគារគឺជាជម្រើសចុងក្រោយបំផុត។

ជាចុងក្រោយ គណនេយ្យភាពដ៏មានប្រសិទ្ធិភាពក៏តម្រូវឲ្យមាននូវសារពត៌មានដ៏រឹងមាំ និងសេរីភាពសារពត៌មានផងដែរ។ នៅក្នុង**ទិវាសេរីភាពសារព័ត៌មានពិភពលោក** ខ្ញុំបានឆ្លុះបញ្ចាំងពីការចូលរួមយ៉ាងសំខាន់របស់ប្រជាជនកម្ពុជាជាមួយប្រព័ន្ធផ្សព្វផ្សាយសង្គម និងសារៈសំខាន់នៃការធានាសេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធផ្សព្វផ្សាយអនឡាញ និងតាមប្រព័ន្ធបោះពុម្ពផ្សាយ។ សេរីភាពនៃការបញ្ចេញមតិ និងការរឹតបន្តឹង ត្រូវបានអនុវត្តលើប្រព័ន្ធផ្សព្វផ្សាយទាំងពីរខាងលើដូចគ្នា។ រដ្ឋាភិបាលបានគូសបញ្ជាក់ពីការពង្រីកប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ប៉ុន្តែទន្ទឹមនឹងនេះ ខ្ញុំក៏សង្កេតឃើញពីការធ្លាក់ចុះនៅក្នុងផ្នែកសារព័ត៌មានផងដែរ និងការស្ទាក់ស្ទើរជារួមក្នុងចំណោមមនុស្សជាច្រើនដែលខ្ញុំបានជួប ក្នុងការសម្តែងមតិជាសាធារណៈ ដែលពួកគេមានការភ័យខ្លាចពីការចាប់ខ្លួន ឬការឃ្លាំមើល។ **ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលក្នុងការបង្កើនលំហសម្រាប់សេរីភាពសារព័ត៌មាន រួមបញ្ចូលទាំងលំហសម្រាប់ដំណើរការដល់អ្នកសារព័ត៌មានឯករាជ្យ ហើយខ្ញុំសូមធ្វើការអំពាវនាវជាថ្មីម្តងទៀត ឱ្យទម្លាក់ចោលការចោទប្រកាន់ទៅលើអតីតអ្នកសារព័ត៌មានរបស់វិទ្យុអាស៊ីសេរីពីររូប ដែលបានរងការចោទប្រកាន់កន្លងមក។**

នៅទីបញ្ចប់ សូមឲ្យមានការបញ្ជាក់មួយកាន់តែច្បាស់ថែមទៀត អំពីសិទ្ធិមនុស្សនៅក្នុងក្របខណ្ឌអភិវឌ្ឍន៍យុទ្ធសាស្ត្ររបស់រដ្ឋាភិបាល និងសកម្មភាពជាក់ស្តែង នឹងជួយគាំទ្រដល់ការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា ដើម្បីឲ្យក្របខណ្ឌ និងសកម្មភាពនេះ មានលក្ខណៈបរិយាប័ន្ន សន្តិភាព និងយុត្តិធម៌ ដោយមិនទុកនរណាម្នាក់ចោលឡើយ។ មិនតែប៉ុណ្ណោះ ក្របខណ្ឌនិងសកម្មភាពនេះនឹងជួយផងដែរដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ (រួមទាំងអ្នកដែលអាចប្រឈមនឹងហានិភ័យនៃការដែលត្រូវបានគេទុកចោល) និងគាំទ្រដល់បំណងប្រាថ្នារបស់ប្រទេសកម្ពុជា ក្នុងនាមជា «កោះសន្តិភាព» ដោយផ្អែកលើគោលការណ៍ប្រជាធិបតេយ្យធានាសិទ្ធិមនុស្ស ឱ្យបានឈានឡើងរីកចម្រើន លូតលាស់ សម្បូររុងរឿង។

**ការអភិវឌ្ឍមួយប្រកបដោយបរិយាប័ន្ន គឺត្រូវមានទាំងក្នុងដំណើរការ ទាំងក្នុងលទ្ធផល។** វប្បធម៌នយោបាយថ្មីមួយ ដែលផ្តោតលើបញ្ហាផ្សេងៗ ការបើកទូលាយចំពោះទស្សនៈខុសគ្នា និងការបញ្ចេញមតិដោយសេរី អាចដើរលើផ្លូវមួយដ៏វែងឆ្ងាយ ក្នុងការធានាអនាគតមួយដែលមានការចែករំលែក ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់។ ក្នុងនាមជាអ្នករាយការណ៍ពិសេស ខ្ញុំនៅតែប្តេជ្ញាចិត្តក្នុងការស្តាប់អ្នកពាក់ព័ន្ធទាំងអស់ដោយមិនលំអៀង និងគាំទ្រកិច្ចពិភាក្សាដែលមានលក្ខណៈបរិយាប័ន្ន ទន្ទឹមពេលដែលខ្ញុំនៅតែបន្តតាមដាន និងធ្វើការតស៊ូមតិ ដើម្បីឲ្យមនុស្សគ្រប់រូបនៅកម្ពុជាទទួលបានសិទ្ធិមនុស្ស។

**ចប់**

***លោកស្រីសាស្ត្រាចារ្យ រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៥ ។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកស្រីគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឯករាជ្យសម្រាប់ឃ្លាំមើលនិងស្វែងរកការពិត របស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញឯករាជ្យផ្នែកសិទ្ធិមនុស្ស ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសណាមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់លើពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិករបស់ អ.ស.ប ទេ ហើយធ្វើការឯករាជ្យពីរដ្ឋាភិបាល និង អ.ស.ប។ ពួកគាត់  បំពេញការងារក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

ឧបសម្ព័ន្ធ

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា**

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា (CSDGs) រួមបញ្ចូលនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាសកល ដែលមានចំនួន ១៧ គោលដៅ ហើយត្រូវបានបន្ថែមដោយគោលដៅទី ១៨ ស្តីពីសកម្មភាពកំចាត់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម សម្រាប់ប្រទេសកម្ពុជា។ ចំណុចដៅទាំងឡាយនៅថ្នាក់ជាតិបាននិងកំពុងត្រូវរៀបចំក្នុងផ្នែកមួយនៃដំណើរការតាក់តែងផែនការមូលដ្ឋានរូបនីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។



<u>គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៦ របស់អ.ស.ប៖ សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ</u>

**គោលដៅទី១៦៖**

លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាបន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព, ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់មនុស្សគ្រប់រូប និងដើម្បីកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន នៅគ្រប់កម្រិតទាំងអស់។

**ចំណុចដៅ នៃគោលដៅទី១៦ (ចំណុចដៅសកល)៖**

១៦.១ កាត់បន្ថយឲ្យបានច្រើនរាល់ទម្រង់នៃអំពើហិង្សា និងអត្រាមរណភាពដោយអំពើហិង្សា នៅគ្រប់ទីកន្លែង។

១៦.២ លុបបំបាត់ការរំលោភបំពាន ការធ្វើអាជីវកម្ម ការជួញដូរ និងរាល់ទម្រង់នៃអំពើហិង្សានិងទារុណកម្មទៅលើកុមារ។

១៦.៣ លើកកម្ពស់វិធានការច្បាប់ នៅកម្រិតជាតិនិងអន្តរជាតិ និងធានាការទទួលបានយុត្តិធម៌ ស្មើភាពគ្នា សម្រាប់មនុស្សគ្រប់រូប។

១៦.៤ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឲ្យបានច្រើននូវលំហូរហិរញ្ញវត្ថុនិងគ្រឿងសព្វាវុធខុសច្បាប់ ពង្រឹងការប្រមូលនិងការប្រគល់នូវទ្រព្យដែលត្រូវបានលួច និង ប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មដែលមានការចាត់តាំងគ្រប់ទម្រង់។

១៦.៥ កាត់បន្ថយឲ្យបានច្រើន រាល់ទម្រង់នៃអំពើពុករលួយនិងអំពើស៊ីសំណូកសូកប៉ាន់។

១៦.៦ រៀបចំស្ថាប័នឲ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៅគ្រប់កម្រិត។

១៦.៧ ធានាឱ្យមានការធ្វើសេចក្តីសម្រេចប្រកបដោយលក្ខណៈឆ្លើយតប បរិយាបន្ន ចូលរួម និងភាពជាតំណាង នៅគ្រប់កម្រិត។

១៦.៨ បើកទូលាយនិងពង្រឹងការចូលរួមរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងស្ថាប័នអភិបាលកិច្ចសកលនានា។

១៦.៩ ត្រឹមឆ្នាំ២០៣០ ផ្តល់អត្តសញ្ញាណកម្មផ្លូវច្បាប់ដល់មនុស្សគ្រប់រូប រួមទាំង ការចុះបញ្ជី កំណើត។

១៦.១០ ធានាការទទួលបានជាសាធារណៈនូវព័ត៌មាន និងការការពារសិទ្ធិសេរីភាពមូលដ្ឋាន ឲ្យស្របតាមច្បាប់ជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិ។

**មធ្យោបាយអនុវត្តគោលដៅទី១៦**

១៦.ក ពង្រឹងបណ្តាស្ថាប័នជាតិពាក់ព័ន្ធ រួមទាំងតាមរយៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បី កសាងសមត្ថភាពនៅគ្រប់កម្រិត ជាពិសេស នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ទប់ស្កាត់អំពើហិង្សា និងការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មនិងឧក្រិដ្ឋកម្ម។

១៦.ខ លើកកម្ពស់និងជំរុញការអនុវត្តច្បាប់និងគោលនយោបាយ ស្តីពីការមិនរើសអើង ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។